ក្រសួងអប់រំ យុវជន និង កីឡា

# ១២ ល្ខោន

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

**វត្ថុបំណង** : និពន្ធ និង សម្ដែងល្ខោន ស្ដីអំពីពលកម្មកុមារ





**លទ្ធផលរំពឹងទុក** : បំផុសគំនិតឱ្យចូលចិត្តសម្ដែងសិល្បៈ និង ផ្ដល់ឱកាសឱ្យកុមារ មានទំនុកចិត្តលើខ្លួនឯងក្នុងការសម្ដែងប្រកបដោយអត្ថន័យ ។

-បង្កើតឱ្យមានវេទិការសម្រាប់ធ្វើសមាហរណកម្មសហគមន៍ និងលើកកម្ពស់សម្បជញ្ញៈ របស់សហគមន៍ ។

## ការកំណត់ពេលវេលា

បង្រៀន ៦វគ្គបូកនិងការហាត់សម និង ពេលវេលាសម្រាប់សម្ដែង។



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់ :

សៀវភៅនេះ គឺជាសៀវភៅដ៏ល្អបំផុតសម្រាប់បន្ថែមអត្ថន័យទៅឱ្យសៀវភៅដែលមានចំណងជើងថា: "រូបភាពការដើរតួ. ការបង្កើតអក្សរសាស្ត្រដោយគំនិតច្នៃប្រឌិត" ។ សៀវភៅត្រូវគេសរសេរដោយផ្អែកទៅលើអ្វីដែលក្រុមបានរៀនសូត្រចេះដឹងដោយសារអារម្មណ៍ដែលពួកគេទទួលបានពីសៀវភៅដែលមានចំណងជើងថា "រូបភាព" ពីការបញ្ចូលពាក្យពេចន៍អក្សរសាស្ត្រទៅក្នុងសៀវភៅដែលមានចំណងជើងថា "ការសរសេរដោយគំនិតច្នៃប្រឌិត" ហើយក្រុមយល់ដឹងអំពីការរៀបចំការសម្ដែងតួ ។ គេមិនទាមទារឱ្យអនុវត្តសៀវភៅនេះឆាប់ពេក មុនឬក្រោយការអនុវត្តសៀវភៅទាំង ៣ ដ៏សំខាន់ ដូចបានបញ្ជាក់មកហើយនោះទេ។ នៅក្នុងប្រទេសខ្លះ មនុស្សពេញវ័យជាពិសេសក្មេងប្រុសយល់ថាវាជាការលំបាកណាស់ក្នុងការគាបសង្កត់ពីកុមារដទៃ ដើម្បីឱ្យពួកគេព្រួយបារម្ភអំពីខ្លួនរបស់គេផ្ទាល់ជាពិសេសកាលណាពួកគេមិនដែលសម្ដែងល្ខោនពីមុនមកនោះ ។ អ្នកត្រូវតែយល់ឱ្យច្បាស់អំពីរបាំងផ្នែកចិត្តសាស្ត្រខាងលើនេះ ហើយជួយដោះស្រាយទម្លុះរបាំងនេះបន្តិចម្ដងៗតាមលំដាប់ ។ នេះគឺការជួយតាមរយៈការប្រើការប្រៀបធៀប

អារម្មណ៍ ដើម្បីឱ្យមនុស្សវ័យក្មេងទាំងនោះយល់ដឹង អំពីបញ្ហាកម្លាំងពលកម្មកុមារ ដោយខ្លួនឯងបន្ទាប់មកប្រើប្រាស់គំនិតច្នៃប្រឌិតក្នុងនិពន្ធអក្សរសាស្ត្រ ដើម្បីជួយឱ្យពួកគេសម្តែងគំនិត និងអារម្មណ៍របស់ពួកគេ ។ បង្កើតការគាំទ្រពីសំណាក់ក្រុមរបស់អ្នក សូមកុំបញ្ជាពួកគេឱ្យគាំទ្រ ។

## ហេតុផល



ការស្រាវជ្រាវជាច្រើនបានបង្ហាញឱ្យឃើញថា ក្នុងការអភិវឌ្ឍន៍និងការសិក្សារឿងល្ខោនមានឥទ្ធិពល និងបទពិសោធន៍ពិសេសតាមរយៈនៃការសម្តែង ។ តាមរយៈវិធីខាងក្រោមក្មេងជំទង់ៗ នឹងទទួលបាននូវអារម្មណ៍ថ្មីៗអំពីជីវិត និងអំពីខ្លួនគេផ្ទាល់ :

-ដោយបណ្តោយខ្លួនឱ្យទៅតាមរឿងប្រឌិត

-ដោយបណ្តោយខ្លួនឱ្យធ្លាក់ ចូលក្នុងស្ថានភាពស្រមើស្រមៃ

-ដោយការយល់ដឹង និងជួបប្រទះ កាលៈទេសៈផ្សេងៗ ស្ថានភាពទ្វេគ្រោះ ជម្រើសនានា និងសកម្មភាពរបស់តួអង្គដែលត្រូវប្រឌិតឡើង ហើយនិងផលវិបាករបស់ពួកគេ ។

-ដោយបង្ហាញឱ្យឃើញរឿងទាំងនោះតាមរយៈបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេរឿងសំខាន់ជាមូលដ្ឋាននៃល្ខោនគឺការបង្កើតសាច់រឿងតាមការសម្តែង ។ ការបង្កើតសាច់រឿង នឹងនាំទៅរកការអភិវឌ្ឍន៍នៃគម្រោងប្លង់សកម្មភាពជាបន្តបន្ទាប់នៃសាច់រឿង និងព្រឹត្តិការណ៍នានា និងប្រធានបទសម្រាប់ការពិចារណាក្នុងករណីនេះសាច់រឿងផ្តោតទៅលើកម្លាំងពលកម្មរបស់កុមារ ។ ក្នុងសៀវភៅដែលមានចំណងជើង "ការសម្តែងតួ" ក្រុមយុវជនបានចាប់ផ្តើមប្រើអារម្មណ៍ខ្លាំងរឿងពលកម្មរបស់កុមារ ។ ក្នុងខណៈនោះសៀវភៅដែលមានចំណងជើងថា "ការបង្កើតអក្សរសាស្ត្រ" នឹងបង្ហាញឱ្យឃើញនូវមូលដ្ឋានគ្រឹះនៃការសម្តែងរឿង ។ ក្រុមទាំងមូលត្រូវបង្កើនការចាប់អារម្មណ៍ និងទទួលខុសត្រូវផ្ទាល់ចំពោះគំនិត និង

គម្រោងដោយបង្កើតរឿងល្ខោនរបស់ខ្លួនគេផ្ទាល់ ។ រឿងល្ខោនគឺជារឿងផ្ទាល់ខ្លួនរបស់ពួកគេ ជាចក្ខុវិស័យរបស់ពួកគេ និងជាសេចក្តីថ្លែងអំពីបំណងរបស់ពួកគេផ្ទាល់ផងដែរ។ សៀវភៅនេះនាំមកប្រើអារម្មណ៍និងទស្សនៈផ្ទាល់ខ្លួនប្រកបដោយកម្រិតខ្ពស់មួយ ។ តាមរយៈការសម្តែងល្ខោនរបស់ពួកគេ ក្មេងៗទាំងនោះនឹងមានឱកាសបញ្ចេញនូវអារម្មណ៍ប្លែកៗ តាមរបៀបគរុកោសល្យ ។ សារៈសំខាន់នៃល្ខោនគឺ "សាច់រឿង" ការប្រឌិតពិភពលោកមួយ ដែលនៅក្នុងនោះតួអង្គខ្លះទទួលផលវិបាកដែលបណ្តាលមកពីស្ថានភាពពិសេស ។ សមាជិកក្រុមនឹងទទួលបន្ទុកសម្តែងសាច់រឿង រឿងសម្តែងនោះហើយនៅពេលគេសម្តែងនោះគេនឹងអាចចង្អុលបង្ហាញឱ្យឃើញលក្ខណៈនៃការសម្តែងតួកាយវិការនៅក្នុងអាចបង្ហាត់ផ្នែករាងកាយ ផ្នែកអារម្មណ៍និងផ្នែកបញ្ញារបស់តួអង្គដែលគេប្រឌិត។ អំពើនឹងស្តែងចេញពីអន្តរកម្មរវាងតួអង្គប្រឌិត និងស្ថានភាពដែលតួអង្គស្ថិតនៅ ។ ល្ខោនផ្តល់នូវផ្លូវមួយទៅរកការសិក្សា និងចាប់យកនូវទំហំចំណេះដឹង បើមិនដូច្នោះទេវាពិតជាមិនអាចចាប់យកដោយវិធីផ្សេងៗទៀតបានទេ ។ វាច្បាស់ណាស់ថា មានការទាក់ទងគ្នាទៅវិញទៅមកក្នុងលោកយើងនេះ ដូចជាការរំលោភសិទ្ធិមនុស្សជាពិសេសលើកម្លាំងពលកម្មរបស់កុមារដែលមិនបានលុបបំបាត់ជាទូទៅ "គឺវាកំពុងតែកើតឡើងនៅកន្លែងខ្លះនៅឡើយ" ។ ត្រូវតែនាំមកនូវការផ្លាស់ប្តូរឥរិយាបថបុគ្គលិកលក្ខណៈសកម្មភាព និង ការយល់ដឹងរបស់មនុស្សទូទៅតាមភូមិសាស្ត្រ និង សេដ្ឋកិច្ចតំបន់នោះ ។ ល្ខោន និងសិល្បៈ គឺជាគន្លឹះសំខាន់ដើម្បីធ្វើឱ្យសម្រេចនូវការផ្លាស់ប្តូរបញ្ហាខាងលើ ។ គោលបំណងនៃអត្ថបទនេះគឺបង្កើននូវចំណេះដឹង ក្នុងចំណោមមនុស្សវ័យក្មេងដើម្បីធ្វើការផ្លាស់ប្តូរ ហើយត្រូវបង្ហាញថាការផ្លាស់ប្តូរត្រូវចាប់ផ្តើមដូចម្តេច ហើយអភិវឌ្ឍន៍ពីចំណុចទាំងនោះដោយរបៀបណា ។ នៅក្នុងសៀវភៅនេះជាពិសេសការយល់ដឹងមានកម្រិតកាន់តែខ្ពស់តាមរយៈការសម្តែងល្ខោនដែលកសាងឡើងដោយពួកគេតែម្តង។ តាមរយៈរឿងល្ខោនពួកគេសម្តែងរឿងផ្ទាល់ខ្លួនប្រាប់ដល់អ្នកទស្សនា ហើយតាមរបៀបនេះគេអាចបង្កើតសម្បជញ្ញៈ និងសមាហរណកម្មនៃសហគមន៍ ។

## អ្វីដែលអ្នកត្រូវការ



ដូចក្នុងសៀវភៅផ្សេងៗទៀតដែរ សំភារៈដែលត្រូវការប្រើគឺមានការកំណត់ច្បាស់លាស់ ។ក្រុមរបស់អ្នកមិនគួរនិពន្ធរឿងល្ខោនដែលតម្រូវឱ្យមានរឿងច្រើនឈុតទេ ដូចការសង់ឆាក ការដាក់បញ្ចូលសម្លេង និងការរៀបភ្លើងច្រើននោះឡើយ ។ វាមានន័យថា ដំណើររឿងគឺផ្អែកទៅលើពលកម្មកុមារ ដែលគេអាចថាជារឿងរបស់គេផ្ទាល់ពួកគេរស់នៅ និង ធ្វើការនៅក្រោមស្ថានភាពយ៉ាប់យ៉ឺន ហើយការសម្តែងល្ខោននេះនឹងឆ្លុះបញ្ចាំងស្ថានភាពជាក់ស្តែងរបស់ពួកគេ ។

ក្រុមរបស់អ្នកគួរសម្តែង ឬធ្វើអ្វីដែលមានតម្លៃ ។ អ្នកប្រហែលជានឹងមានសំណាងគ្រប់គ្រាន់ព្រោះបានចូលសម្តែងក្នុងរោងល្ខោន ឬក៏សម្តែងនៅលើឆាកល្ខោនដ៏ធំទូលាយ ។ តាមពិតអ្នកប្រាកដទាមទារការងារខ្លះនៅក្នុងថ្នាក់ ដើម្បីរៀបចំសរសេរសាច់រឿងសម្រាប់សម្តែងជាដើម ។ ចរិកលក្ខណៈនៃសាច់រឿងនឹងកំណត់ថាត្រូវប្រើសម្ភារៈអ្វីខ្លះ ហើយមានអ្វីទៀតជាតម្រូវការសម្រាប់សាច់រឿងនោះ ។ ម្យ៉ាងទៀតវាក៏អាស្រ័យទៅលើស្ថានភាពបរិយាកាសជាក់ស្តែងនៅក្នុងតំបន់អ្នកអាចនឹងមានដំណើរការជាមួយនឹងក្រុមនៅខាងក្រៅក្នុងបរិយាកាសដ៏ស្ងប់ស្ងាត់មួយ ។ សៀវភៅនេះតម្រូវឱ្យក្រុមទាំងមូលរួមសហការគ្នា ។ អ្នកមិនត្រូវបំបែកគ្នាជាក្រុមតូចៗ ឬ ស្វែងរកទីកន្លែងណាមួយដោយឡែកពីគ្នាដើម្បីធ្វើការនោះឡើយ ។



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សៀវភៅនេះគឺនាំឱ្យមានការនឿយហត់ ទាំងអ្នក និង ក្រុមរបស់អ្នក។ អ្នកអាចសម្រាកច្រើនដងក្នុងតំណាក់កាលតាក់តែងនិពន្ធ និង ក្នុងតំណាក់កាលហាត់សម្តែង។ សម្រាប់ក្មេងៗ វាពិតជាពុំអាចផ្តោតអារម្មណ៍ក្នុងរយៈពេលវែងបានឡើយហើយពួកគេត្រូវការ ពេលវេលាឈប់សម្រាកខ្លះ និងពេលកំសាន្ត បើមិនដូច្នោះទេអ្នកអាចនាំពួកគេងាកទៅរកភាពបរាជ័យបាន ។ ការឈប់សម្រាកជាញឹកញាប់ ធ្វើឱ្យពួកគេនៅតែមានការផ្តោតអារម្មណ៍ ហើយពួកគេពេញចិត្តនិងយកចិត្តទុកដាក់ចំពោះអ្នកដែលគិតដល់សុខភាព និងសុខមាលភាពរបស់ពួកគេ។ សូមផ្តល់ពេលវេលាឱ្យពួក

គេប្រឹងប្រែងដោយខ្លួនឯង ហើយផ្តល់ចំណីអាហារដ៏សមរម្យដើម្បីរក្សាកម្លាំងរបស់ពួកគេឱ្យបានល្អក្នុងការហាត់សម ។ ធ្វើយ៉ាងណាឱ្យពួកគេសម្រាកបានស្រួលល្អមុនពេលសម្តែង។ ផ្តល់ដំបូន្មាន ឱ្យពួកគេថែទាំសុខភាព និង សុខមាលភាពក្នុងកំឡុងពេលដ៏នឿយហត់នោះ ហើយក៏កុំភ្លេចគិតពីសុខភាពរបស់អ្នកផងដែរ !

## ការរៀបចំ



បើអាច សូមស្វែងរកកន្លែងណាដែលសមរម្យ និង កន្លែងណាដែលមានទំនាក់ទំនងល្អ ហើយជាការល្អសូមឱ្យមានពំនោលក្នុងឈុត និងសូមធ្វើការស្រាវជ្រាវរឿងដើម្បីធ្វើយ៉ាងណាឱ្យមានលក្ខណៈគរុកោសល្យ ។ ប្រសិនបើសាច់រឿងជាផ្នែកមួយក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ អ្នកអាចរកឃើញនូវការគាំទ្រមួយចំនួនក្នុងសៀវភៅអប់រំដើម្បីជួយអ្នកក្នុងការអនុវត្តន៍ការងារនេះ ។ តែប្រសិនបើមិនអាចរកការគាំទ្របានទេនៅមានវិធីផ្សេងទៀតដែលអ្នកអាចរកបាន ដូចជាមាននៅក្នុងស្នាដៃនិពន្ធរឿងល្ខោនដែលអាចរកបានតាមរយៈបណ្ណាល័យសាធារណៈ ឬស្ថាប័នអប់រំ ឬតាមអ៊ីនធឺណិត ។ ជាងនេះទៅទៀតអ្នកអាចស្គាល់នរណាម្នាក់ ដែលមានបទពិសោធន៍ផ្នែកខាងល្ខោនអប់រំដែលអាចឱ្យអ្នកខ្ចីនូវសម្ភារ និងផ្តល់ការគាំទ្រក្នុងការអនុវត្តន៍សៀវភៅនេះ។

## ជំនួយពីខាងក្រៅ

លុះត្រាតែអ្នកជាគ្រូដែលមានបទពិសោធន៍ខាងផ្នែកល្ខោន ហើយបានធ្វើការនេះ ឬអ្នកមានចំណង់យ៉ាងខ្លាំងក្នុងវិស័យសិល្បៈនេះទើបអ្នកអាចកំណត់នូវការគាំទ្រពីខាងក្រៅ ដើម្បីឱ្យជួយអនុវត្តន៍សៀវភៅនេះបាន ។ ទោះជាអ្នកមានការជឿជាក់លើខ្លួនឯងយ៉ាងណាក៏ដោយ ក៏អ្នកត្រូវនិយាយទៅកាន់នរណាមួយដែលមានបទពិសោធន៍ ឬ ទទួលដំបូន្មានពីអ្នកដែលមានអាជីពខាងផ្នែកនេះ ។

វិសាលភាពក្នុងការស្វែងរកការគាំទ្រពីខាងក្រៅ គឺអាស្រ័យទៅលើគោលបំណង និង កម្មវត្ថុនៃក្រុមទាំងមូលក្នុងការអភិវឌ្ឍន៍រឿងណាមួយ។ ឧទាហរណ៍ : ប្រសិនបើរឿងនោះត្រូវសម្តែងសម្រាប់ទស្សនិកជនក្នុងគោលបំណង លើកកម្ពស់ការងារក្នុងក្រុម (នេះគឺជាករណីមួយ) អ្នកនិងក្រុមរបស់អ្នកនឹងទទួលបាននូវផលប្រយោជន៍ អំពីបទពិសោធន៍នៃការនិពន្ធនិងជំនាញផ្នែកល្ខោននោះ ។ អ្នកជំនាញ

ល្ខោនខ្លះអាចជួយទាំងផ្នែកនិពន្ធ និង ផ្នែកសម្តែង ។ ប្រសិនបើអ្នកមានជំនួយក្នុងការនិពន្ធ និងការសម្តែង គឺត្រូវស្វែងរកមើលថាតើអ្នកដដែលនោះអាចនិងជួយអ្នក និងក្រុមរបស់អ្នកម្តងទៀតដែរឬទេ ក្នុងករណីដែលអ្នកត្រូវការនោះ ។

សូមចំណាំផងដែរថា អ្នកអាចទាក់ទងជាមួយ និងអ្នកអាជីពផ្នែកល្ខោននេះ មិនមែនមានន័យថាអ្នកចាំបាច់ត្រូវចំណាយលើអ្នកទាំងអស់នោះទេ ។ ពិតណាស់ថាមនុស្សគ្រប់គ្នាត្រូវការប្រាក់ដើម្បីជីវិតរស់នៅ និង គួរតែចំណាយលើសេវាកម្មរបស់ពួកគេ ប៉ុន្តែប្រសិនបើអ្នកជំនាញនោះស្គាល់អ្នកឬក៏ស្គាល់នរណាម្នាក់ក្នុងក្រុម ឬក៏គាត់ជាមនុស្សម្នាក់ដែលមានឆន្ទៈក្នុងយុត្តិធម៌សង្គម ពេលនោះហើយគាត់ ឬក៏អ្នកទាំងនោះ និងមានឆន្ទៈជួយអ្នកដោយមិនគិតកម្រៃ ឬក៏យ៉ាងហោចណាស់ក៏បានចុះថ្លៃខ្លះដែរ ។ សូមកុំខ្លាចក្នុងការសួរ និងពន្យល់បញ្ជាក់អំពីគោលបំណង និងកម្មវត្ថុនៃការផលិតរឿងល្ខោន ។ បើគ្មានការសួរនាំក៏គ្មានការរីកចម្រើនដែរ ។



## សកម្មភាព ១ : ការសរសេររឿងល្ខោន
## បង្រៀន ៣ ពេល



មានសាលាពីរដែលគិតពិចារណាលើការនិពន្ធ ។ អ្នកអាជីពល្ខោនខ្លះមានទស្សនៈផ្ទុយនិងគោលការណ៏ដែលហាមឃាត់នូវសេរីភាពក្នុងការបញ្ចេញមតិចំណែកខ្លះទៀតយល់ថា សេរីភាពបញ្ចេញមតិអាចបង្កើតទំនុកចិត្តដល់មនុស្សវ័យក្មេងនៅលើឆាកជាពិសេសក្រុមក្មេងៗដែលមិនដែលមានពិសោធន៏ផ្នែកល្ខោននោះ ។ បទពិសោធន៏របស់យើង ក្នុងដំណាក់កាលសាកល្បងនោះបានបង្ហាញថា ក្មេងភាគច្រើនដែលមានបទពិសោធន៏តិច ឬក៏គ្មានពិសោធន៏ទាក់ទង និង ការសម្តែងល្ខោនហើយមានអត្ថបទល្ខោននៅក្នុងដៃអាចមានការងាយស្រួលខ្លះក្នុងពេលសម្តែង ។ អត្ថបទសាច់រឿងនោះមិនមានន័យថា តួដែលសម្តែងចាំបាច់ត្រូវតែចាំឥតខ្ចោះនោះឡើយ ហើយក៏មិនត្រូវធ្វើឱ្យខុសឆ្ងាយពេកនោះដែរ ។ និយាយរួមការបង្កើតសាច់រឿងគឺមានន័យថាត្រៀមទុកជាមុននូវអ្វីដែលយើងសម្តែងសមជាមួយនឹងក្រុម ។

កត្តាផ្សេងៗមានឥទ្ធិពលទៅ លើគំនិតដែលគេប្រើក្នុងពេលដែលគេសរសេរសាច់រឿង ។ ដើម្បីឱ្យមានប្រសិទ្ធិភាពសាច់រឿងនោះគឺជារឿងដែលយកទៅសម្តែងនៅលើឆាក ។ សាច់រឿងគួរផ្អែក លើបទពិសោធន៏ជីវិតពិតរបស់អ្នកណាម្នាក់ដែលអាចជាសមាជិកក្នុងក្រុមតួសម្តែងនោះ ។ ប្រហែលជាមានអ្នកខ្លះក្នុងចំណោមពួកគេធ្លាប់ធ្វើការ ឬឆ្លងកាត់បទពិសោធន៏កុមារពលកម្មក្នុងទម្រង់ណាមួយនៅពេលដែលពួកគេជាក្មេង ។ សាច់រឿងនោះអាចជារឿងមួយដែលជាស្នាដៃនិពន្ធរបស់សមាជិកណាម្នាក់នៅក្នុងក្រុមរបស់អ្នកគេបានសរសេរកំឡុងពេលដែលយើងឱ្យ ធ្វើជាលំហាត់គេនិពន្ធរឿងប្រឌិត ឬ ក៏ជារឿងដែលបានមកពីបទពិសោធន៏ក្នុងក្រុមនៅពេលដែលពួកគេសម្តែងផ្សេងគ្នាជាដើម ។ ឧទាហរណ៏: មនុស្សពីខាងក្រៅម្នាក់អាចនឹងចូលមកក្នុងក្រុមហើយគាត់បាននិយាយជាច្រើនស្តីអំពីការប្រើប្រាស់ពលកម្មកុមារ និង ស្ថានភាពផ្សេងរបស់ពួកគេ ហើយគាត់បានធ្វើឱ្យមានចំណាប់អារម្មណ៏ចុងក្រោយបំផុតចំពោះក្រុម ។

## ការសរសេររឿងល្ខោនជាឈុត

គំនិតនៅពេលនេះគឺបង្កើតឈុតសម្រាប់រឿងល្ខោនរបស់អ្នកដោយផ្អែកលើវិធីការទាំង៤ ។ ជាបឋមការ១ គឺបង្កើតរឿងល្ខោនការ២ និង ការ៣ គឺសរសេរសាច់រឿង ហើយការ ៤ គឺសាច់រឿងបញ្ចប់ ។ សាច់រឿងទាំងមូលនេះត្រូវបង្កើតបន្តគ្នាពីការ១ ដល់ការ៤ ។ សូមមើលគំរូនៃការនិពន្ធដែលមានលម្អិតនៅក្នុងលំហាត់នេះ ។

ដោយផ្អែកលើមូលដ្ឋានគ្រឹះ សំខាន់ៗបំផុតនៃបទពិសោធន៍ក្នុងគម្រោងកំណត់កាលបរិច្ឆេទជំរុញឱ្យក្រុមទាំងមូលផ្តល់គំនិតម្នាក់ម្តងៗជំរុញគំនិតសំខាន់ ដែលយើងចង់បានដោយរួមបញ្ចូល :

-**សារ(ព័ត៌មាន)** : តើព័ត៌មានអ្វីដែលក្រុមប្រាថ្នាចង់សម្តែងបង្ហាញទស្សនិកជន? តើទស្សនិកជនចង់ជួយគាំទ្រឬទេ ? តើពួកគេចង់បំភ័យទស្សនិកជនដែរឬទេ ? តើពួកគេមានបំណងចង់ឱ្យទស្សនិកជនរំជួលចិត្តដែរឬទេ?

-**ការរៀបចំ** : រៀបចំទីតាំងភូមិសាស្រ្ត និងទីកន្លែងសម្តែង។ ថាតើក្មេងៗមានចំណាប់អារម្មណ៍ជាមួយនិងការសម្តែងរបស់ក្មេងៗដូចគ្នាឬទេ ? តើពួកគេជាក្មេងតាមចិញ្ចើមថ្នល់ឬ ? ពួកគេនៅផ្ទះឬ ? តើពួកគេទៅសាលា ឬក៏ទៅធ្វើការ ?

-**ចរិកលក្ខណៈផ្សេងៗ** : កុមារពលកម្ម និយោជិក មាតាបិតាអ្នកជិតខាង មិត្តភក្តិសត្រូវ ។ល។ តើឈ្មោះអ្វីខ្លះនឹងត្រូវប្រើសម្រាប់ពួកខាងលើនេះ។

-**ការបើកឆាក** : តើការសម្តែងនេះគប្បីប្រើរូបភាពដូចម្តេចដែរ ?

-**ការបិទឆាក** : តើក្រុមទាំងមូលចង់បញ្ចប់សាច់រឿងដូចម្តេចដែរ ? តើមានលក្ខណៈជាវិជ្ជមានដែរឬទេ ?

-**ការចូលរួម** : តើក្រុមទាំងមូលចង់ចូលរួមសម្តែងទាំងអស់គ្នាឬទេ ? តើគេ នឹងត្រូវការជំនួយក្នុងការគ្រប់គ្រងឆាកឬទេ ?

-**មាតិការ** : តើនឹងត្រូវមានភ្លេង ចម្រៀង និង ការរាំ ឬទេ ?



ទាំងនេះគឺជាចំណុចត្រួតពិនិត្យមួយចំនួនលើបញ្ហាដែលអ្នកគួរតែលើកឡើងនៅពេលធ្វើលំហាត់ស្រង់យោបល់ ។ ជាអ្នកអប់រំ អ្នកគួរតែចាំនៅក្នុងចិត្តថា តាមរយៈកម្មវិធី IPEC ការឆ្លើយតបដ៏មានសង្ឃឹមគួរត្រូវធ្វើឱ្យបានខ្លាំងក្លា ។ ដោយអនុវត្តន៍តាមសៀវភៅទាំងនេះ អ្នកនិងក្រុមរបស់អ្នកបានផ្តល់នូវសេចក្តីសង្ឃឹមយ៉ាងមាំចំពោះយុទ្ធនាការឃោសនា ពិភពលោកដើម្បីបំបាត់ចោលការប្រើប្រាស់កម្លាំងពលកម្មកុមារក្នុងពិភពលោក ។ ក្នុងក្តីសង្ឃឹមកើតមានឡើងក្នុងលំហាត់គរុកោសល្យ នេះការសម្តែងល្ខោនបានជះឥទ្ធិពលទ្វេដងចំពោះទស្សនិកជនតាមរយៈការសម្តែងនិងអត្ថាធិប្បាយអំពីសង្គមបានច្រើនជាអតិបរិមានិងទាញយកនូវផល ប្រយោជន៍ ។

-លើកទឹកចិត្តក្រុមក្មេងៗនៅក្នុងក្រុមរបស់អ្នក ដើម្បីឱ្យពួកគេបញ្ចេញមតិនិងផ្តល់នូវគំនិតល្អៗ ។ សកម្មភាពទាំងនោះគឺជាផ្នែកមួយនៃល្ខោនជាគំនិតរបស់ពួកគេផ្ទាល់ ហើយពួកគេមានឱកាសបញ្ចេញមតិផ្ទាល់ស្តីអំពីបញ្ហាសំខាន់ពាក់ព័ន្ធទៅនិងមនុស្សទាំងអស់ក្នុងពិភពលោក។

-កំណត់ត្រាចំណាំនៃគំនិត និងយោបល់នៅលើក្តារខៀនឬនៅលើក្រដាសធំៗ ។ មតិយោបល់ខ្លះបានងាកចេញពីប្រធានបទនៃការពិភាក្សា ឧទាហរណ៍ក្រុមពិភាក្សាចាប់ផ្តើមងាកចេញពីកម្មវត្ថុឬគំនិតល្អៗ ដូច្នេះអ្នកត្រូវនាំការពិភាក្សាត្រឡប់មករកគំនិត ដែលយើងចង់បានវិញហើយបន្ទាប់មកឱ្យក្រុមពិភាក្សាបានឈប់សម្រាកមួយភ្លែតដើម្បីអ្នកមានឱកាសសង្ខេបគំនិតល្អៗដែលក្រុមបានផ្តល់ឱ្យ។ បន្ទាប់មកទៀតអ្នកគួរតែជួយក្រុមក្នុងការបង្កើតការវទាំង៤នៃសាច់រឿង។ ត្រូវដឹងឱ្យច្បាស់ថាគ្រប់ៗគ្នាបានបញ្ចេញយោបល់ និងពាក់ព័ន្ធផ្ទាល់ក្នុងរឿងនេះ ហើយក្រុមឬអ្នកទាំងនោះបានចូលរួមទាំងអស់គ្នា។

## និពន្ធរឿង



នៅពេលដែលក្រុមរបស់អ្នកមានគម្រោងការបង្កើតសាច់រឿងល្ខោនយើងត្រូវជំរុញវាឱ្យកើតឡើង ។ សកម្មភាពអាចធ្វើដោយក្រុមធំ ឬក្រុមតូចៗជាច្រើន ។ ការសរសេរនិពន្ធចាំបាច់តម្រូវឱ្យមានការផ្លាស់ប្តូរពាក្យសម្តីឬកពារ សកម្មភាព (កាយវិការ) និង ទីតាំងដែលត្រូវឈរសម្តែង ហើយវាក៏ត្រូវការចាំបាច់ផង



ដែរនូវសាច់រឿងចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។ ក្រុមទាំងមូលអាចក្លាយជាផ្នែកណាមួយនៃលំហាត់នេះ ហើយរឿងនេះត្រូវការផងដែរនូវការដឹកនាំយ៉ាងប៉ិនប្រសព្វរបស់អ្នក ម្យ៉ាងទៀតប្រសិនបើពួកគេចង់ក្លាយទៅជាផ្នែកមួយនៃវិស័យនេះ នេះគឺជាសញ្ញាវិជ្ជមានមួយដែលត្រូវស្វាគមន៍ ជាថ្មីម្តងទៀតអ្នកត្រូវតែកត់សំគាល់ផ្ទាល់ខ្លួនថាវាជាការល្អណាស់ ដែលអ្នកត្រូវស្នើសុំម្នាក់ ឬ ពីរនាក់ក្នុងក្រុមឱ្យធ្វើការស្ម័គ្រចិត្ត ដើម្បីកត់ត្រារាល់គំនិតយោបល់ដែលក្រុមបានពិភាក្សាសម្រេចរួចហើយនោះដើម្បីកុំឱ្យបាត់ ឬភ្លេចចំណុចល្អទាំងនោះដែលជាគំនិតល្អក្នុងសាច់រឿងដូច្នេះគេអាចសរសេរ សាច់រឿងបាន។

លទ្ធភាពផ្សេងទៀតគឺថាប្រសិនបើក្រុមនោះវាធំពេក ឧទាហរណ៍ជាង ១០ នាក់ យើងគួរតែបំបែកឱ្យទៅជាក្រុមតូចៗដែលអាចមានគ្នា២នាក់ ឬ ៣ នាក់ ប៉ុន្តែមិនត្រូវឱ្យលើសពី ៥ នាក់ ឡើយ ។ ក្រុមតូចទាំងនេះត្រូវធ្វើនូវការងារជាក់លាក់ផ្សេងគ្នា ។ ឧទាហរណ៍ៈ គេអាចសុំឱ្យក្រុមមួយបង្កើតតួអង្គផ្សេងៗ ក្រុមផ្សេងទៀតឱ្យរៀបចំឈុតចាប់ផ្តើម "ឈុតបើកឆាក" ក្រុមផ្សេងទៀត ឱ្យធ្វើសាច់រឿងផ្ទាល់ ។ល។ បើមិនដូច្នោះទេអ្នកអាចសុំឱ្យក្រុមនីមួយៗ តែងរឿងដោយខ្លួនឯងផ្ទាល់ បន្ទាប់មកអ្នកអាចមានអត្ថបទសាច់រឿងជាច្រើន ។ នេះអាចជាលំហាត់គួរឱ្យចាប់អារម្មណ៏មួយព្រោះថាអត្ថបទសាច់រឿងទាំងនោះ
អាចនឹងត្រូវគេបញ្ចូលគ្នាដើម្បីបង្កើតនូវអ្វីដែលក្រុមបានគិតថាជាសាច់រឿងដ៏ល្អបំផុតមួយ ។ សូមចាំថាវាជា រឿងរបស់ពួកគេហើយវាជាការងាររបស់ពួកគេ ។

## វគ្គព្រាងបញ្ចប់

ក្នុងទម្រង់បែបណាក៏ដោយអ្នកត្រូវយករឿងនោះមកបង្កើតជារឿងឈុតខ្លីៗដែលនៅពេលណាមួយឈុតទាំងនោះនឹងត្រូវកែលម្អរឡើងវិញ និងត្រូវបញ្ចូលគ្នាដើម្បីបង្កើតនូវសាច់រឿងចុងក្រោយមួយសម្រាប់ការសម្តែង ។ ទៅតាមការរីកចម្រើនរបស់អ្នកជាមួយនិងលំហាត់នេះអ្នកនឹងឃើញក្រុមនោះស្តែងចេញមកនូវគំនិតដើមរបស់ពួកគេ និងឈុតឆាកពោរពេញដោយមហិច្ឆតារបស់ពួកគេ។ ជាថ្មីម្តងទៀតការចង់បានដោយសារប្រកបដោយមហិច្ឆតាលោភលន់ដោយគ្មានការសម្របសម្រួលបទពិសោធន៏បង្ហាញថាសមត្ថភាពក្រុមក្នុងការសម្តែងល្ខោនដោយបទពិសោធន៏នៅមានកំណត់នេះគឺមិនអាចធ្វើទៅបានទេ។ ដោយពួកគេបានសរសេរសាច់រឿងហើយក្រុមនោះត្រូវតែមានឱកាសសម្តែងឱ្យអស់ពីសមត្ថភាពរបស់ពួកគេ



ដើម្បីឱ្យពួកគេមានអារម្មណ៍សុវត្ថិភាពចំពោះចំណេះដឹង ដែលពួកគេបានទទួល ពីការគាំទ្រយ៉ាងពេញលេញរបស់អ្នកនោះ ។ទោះនៅក្នុងករណីណាក៏ដោយសាច់រឿងនៃលំហាត់នោះគឺមិនមានបំណងផលិតឈុតពិសេសណាមួយដែលនឹងនាំឱ្យពិភពល្ខោនរីងស៊ុងនោះឡើយ ប៉ុន្តែចូរកុំដកចេញនូវលទ្ធភាពនេះ ។ សៀវភៅល្ខោន គឺជាការពង្រឹងសមត្ថភាពគរុកោសល្យ និង លើកកម្ពស់ការយល់ដឹងមនុស្សវ័យក្មេង ស្តីពីការប្រើកម្លាំងកុមារពលកម្ម ។ នេះជាអត្ថន័យពិតប្រាកដរបស់ល្ខោនចំណុចសំខាន់មួយទៀតនៃការសម្តែងគឺទាក់ទាញនឹងផ្តល់នូវលទ្ធផលជាច្រើនជូនដល់ទស្សនិកជនគ្រប់រូប ។

វគ្គចុងក្រោយនៃការព្រាងនេះគួរឱ្យក្រុមនីមួយៗ ផ្តល់នូវឆាកផ្សេងៗគ្នាព្រមទាំងតួអង្គផងត្រូវមានការសម្រេចចិត្តថាតើតួអង្គទាំងនោះ ត្រូវនិយាយរបៀបណានៅក្នុងសាច់រឿង ហើយថាតើតួអង្គត្រូវសម្តែងសកម្មភាពអ្វី ។ ត្រូវសម្រេចថាតើត្រូវមានបទភ្លេងចម្រៀង ឬការរាំឬទេ ?

ត្រូវផ្តោតលើអ្វីដែលក្រុមបានសម្រេចលើសាច់រឿង ដែលគេចង់ឱ្យទស្សនិកជនទស្សនា ។ លើកទឹកចិត្តក្រុមឱ្យតួអង្គប្រើពាក្យល្អៗ ។ ប្រសិនបើតួអង្គជាមនុស្សក្មេងៗ គេគួរប្រើពាក្យ និងភាសាដែលក្រុមអាចយល់បាន ហើយពួកគេត្រូវនិយាយដោយខ្លួនឯង ។ ពាក្យទាំងនោះត្រូវពោលចេញមកតាមបែបធម្មជាតិ ហើយពួកគេគួរបញ្ចេញអារម្មណ៍ពិតៗ ។ អ្នកគួរមានតួនាទីគាំទ្រនិងជាពាក្យប្រឹក្សានៅក្នុងដំណើរការនេះ ។ ឧទាហរណ៍ ប្រសិនបើឆាកណាមួយមិនសមគ្នាទៅ និងឆាកមួយទៀតនោះអ្នកត្រូវប្រាប់ឱ្យក្រុមដឹង និងជួយពួកគេឱ្យបង្កើតទំនាក់ទំនងឆាកឱ្យ បានល្អ ។

នេះគឺជាដំណាក់កាលរៀបចំចុងក្រោយដែលអ្នកត្រូវរកការគាំទ្រខាងក្រៅ ។ អ្នកសម្តែង ឬអ្នកនិពន្ធល្ខោនគួរជួយក្រុមទាំងនោះឱ្យកែលម្អសាច់រឿង និងរៀបចំឆាក ។ ទោះជាយ៉ាងណាក៏ដោយគួរចាំថា ចំណុចនៃលំហាត់គឺមិនមែនជាការបញ្ចប់ដោយគ្រាន់តែ មានអត្ថបទសាច់រឿងនិងគុណភាពប៉ុណ្ណោះទេក៏ប៉ុន្តែជាដំណើរការផលិតអត្ថបទសាច់រឿងនិងកម្រិតនៃការពាក់ពន្ធ័របស់ក្រុមនីមួយៗផងដែរ ។ ក្រុមរបស់អ្នកអាចនិពន្ធរឿងល្ខោន ក្នុងទម្រង់ផ្សេងៗគ្នាតាមរយៈលំហាត់នេះ ។ រឿងជាច្រើនអាស្រ័យលើទម្រង់នៃក្រុមទំនាក់ទំនងរបស់ពួកគេ ព័ត៌មានដែលពួកគេ



## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

គោលការណ៍"ខ្លី និងត្រូវចំណុច" គឺជាគោលការណ៍ដែលទាក់ទងនៅក្នុងជំពូកនេះ ។ រយៈពេលនៃការយកចិត្តទុកដាក់របស់ទស្សនិកជនអាចមានកំណត់ហើយរយៈពេលអតិបរមាសម្រាប់ការសម្តែងទាំងស្រុងមានត្រឹម ២០នាទីដល់ ៣០នាទីជាការប្រសើរដែលគេត្រូវការ ។ ចងចាំនូវសមត្ថភាពផ្ទាល់ខ្លួនក្នុងការរៀបចំការហ្វឹកហាត់ ។ ជាពិសេសទៅទៀតប្រសិនបើបទពិសោធន៍របស់ក្រុមល្ខោនមានកម្រិត ។ ពួកគាត់ប្រហែលជាដឹងថាតើការហ្វឹកហាត់នេះជួបការលំបាកបែបណា, មានរយៈពេលប៉ុន្មាន និងត្រូវធ្វើឡើងវិញយ៉ាងដូចម្តេច ។ ពួកគាត់ប្រហែលជាយល់ថាការហាត់សមទាំងនេះបង្ករឱ្យមានភាព"ធុញទ្រាន់" ។ក្រុមនេះនឹងតម្រូវឱ្យសិក្សាស្វែងយល់អំពីការហ្វឹកហ្វាត់ព្រមទាំងការសម្តែងអ្វីដែលរឿងល្ខោនពិតជាត្រូវរាប់បញ្ចូល ។

ចង់ផ្តល់ឱ្យទីតាំងភូមិសាស្ត្រ វប្បធម៌ក្នុងស្រុក និងប្រពៃណី។ ឧទាហរណ៍ : ក្រុមអាចនិពន្ធ:

-ការសម្តែងដែលពាក់ព័ន្ធសមាជិកទាំងអស់នៅក្នុងក្រុម

-ការសម្តែងដែលពាក់ព័ន្ធក្រុមភាគច្រើនក្នុងខណៈដែលក្រុមដទៃទៀតផ្តល់នូវសាច់ ភ្លេង ឬការរៀបចំឆាក ។

-ការសម្តែងតាមរយៈកាយវិការដោយមិនចាំបាច់ប្រើអត្ថបទឡើយ

-ការសម្តែងរឿងខ្លីៗដែលសម្តែងដោយតួតែ១ ឬតួច្រើន

-ចម្រៀងមួយដែលច្រៀងដោយសមាជិកក្រុមមួយចំនួន ឬទាំងអស់គ្នា

-ការសម្តែងដែលពាក់ព័ន្ធ នឹងតួអង្គសំខាន់ណាមួយ ឬតួឯក ២នាក់

ទម្រង់នៃការសម្តែងមានច្រើនគ្មានទីបញ្ចប់ឡើយ ការសម្តែងទាំងនោះជាលទ្ធផលនៃការងាររបស់ក្មេងៗទាំងនោះ ហើយពួកគេមានអារម្មណ៍យល់ដឹងថានេះ ជាការងាររបស់គេផ្ទាល់។ បទភ្លេងក៏ដូចជារឿងល្ខោនបានពុះពារឆ្លងកាត់គ្រប់ព្រំដែន ដោយបង្ហាញឱ្យឃើញអត្តសញ្ញាណវប្បធម៌ ហើយគេអាចប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការឃោសនា។ ក្រុមរបស់អ្នកអាចពិចារណាថាតើត្រូវបញ្ចូលបទភ្លេងចម្រៀងនឹងរបាំនៅក្នុងឈុតមួយនៃរឿង ឬក៏ត្រូវប្រើភ្លេងណាមួយដោយឡែក។

រឿងបញ្ចូលឧបករណ៍ភ្លេងដែលមាននិងឧបករណ៍ផ្សេងទៀតអាស្រ័យទៅលើការយល់ព្រមរបស់ក្រុម។ សូមទុកឱ្យក្រុមសម្រេចនូវអ្វីដែលពួកគេចង់ធ្វើ ។

ចាប់តាំងពីតំណាក់កាលនេះតទៅក្រុមត្រៀមលក្ខណៈជាស្រេច ដើម្បីសម្តែងរឿងល្ខោនតាមអត្ថបទសាច់រឿងរបស់ពួកគេ។ រយៈពេលសម្តែងអាស្រ័យលើការសម្រេចចិត្តរបស់ក្រុមស្តីពីបំនងយ៉ាងណានៅក្នុងលំហាត់នេះ

-តើគេត្រូវសម្តែងនៅក្នុងក្រុមសម្រាប់តែក្រុមប៉ុណ្ណោះឬ ?

-តើត្រូវសម្តែងសម្រាប់សាលាមួយសម្រាប់ពួកគេឬសម្រាប់សាលាផ្សេងជិតៗនោះដែរ?

-តើត្រូវសម្តែងសម្រាប់សហគមន៍មួយ ឬសម្រាប់សហគមន៍ច្រើន ?

-តើត្រូវសម្តែងនៅក្នុងរោងល្ខោន នៅក្នុងសាលសាលា នៅក្នុងបន្ទប់ធំ ឬ កណ្តាលវាល ?

-តើត្រូវផ្សាភ្ជាប់ជាមួយរឿងល្ខោននៅក្នុងស្រុកឬទេ ?

-តើវាជាផ្នែកមួយនៃមហោស្រពនៃសិល្បៈឬត្រូវចូលរួមប្រកួតប្រជែងសិល្បៈ ឬទេ?

-តើវាជាការសម្តែងតែមួយលើក ឬជាការសម្តែងច្រើនលើកសម្រាប់ទស្សនិកជនផ្សេងៗគ្នា ?

-តើត្រូវគេប្រើប្រាស់សម្រាប់ការឃោសនាលើកកម្ពស់ការយល់ដឹងដែលក្រុមបានរៀបចំឬ ?

-តើផ្នែកសារព័ត៌មានត្រូវបានគេអញ្ជើញឱ្យចូលរួមការសម្តែងឬទេ ?

អ្វីទាំងអស់អាស្រ័យលើលើការសម្រេចចិត្តរបស់ក្រុមទៅលើអ្វី ដែលអាចប្រើប្រាស់បានខ្លះ ទីកន្លែង ធនធាន ការគាំទ្រ ប្រជាជន ការតាំងចិត្ត ។ល។ ករណីនីមួយៗ គឺខុសៗគ្នាហើយដំបូន្មានរបស់យើង គឺចង់ឱ្យរឿងល្ខោននោះក្លាយជាមធ្យោបាយសំខាន់សម្រាប់លើកកម្ពស់ការយល់ដឹងនឹងផ្តល់នូវអំណាចដល់មនុស្សវ័យក្មេងទាំងនោះ។ សូមយកចិត្តទុកដាក់នឹងធ្វើយ៉ាងណាឱ្យក្រុមមនុស្សវ័យក្មេងទាំងនោះមានមហិច្ឆិតា ។ គេនឹងទទួលបាននូវចំណេះដឹងជាច្រើនពីលំហាត់ពាក់ពន្ធ័នឹងឥរិយាបថផ្ទាល់របស់ពួកគេ និង ការអភិវឌ្ឍន៍សង្គម ។ ឥរិយាបថ ការសម្តែងជំនឿ និងបុគ្គលិកលក្ខណៈរបស់ពួកគេនឹងត្រូវផ្លាស់ប្តូរជារៀងរហូត ហើយការឃោសនាជាសកល ស្តីពីការលុបបំបាត់ពលកម្មរបស់កុមារពិតជានឹងទទួលផលប្រយោជន៍យ៉ាងខ្លាំង។

## ការបែងចែកការសម្តែង

គ្រប់ៗគ្នានៅក្នុងក្រុមគួរមានឱកាសនិយាយក្នុងការសម្រេចចិត្តថាអ្នកណាលេងអ្វី ហើយនរណាធ្វើអ្វី ? ។ តួនាទីនៃការអប់រំគួរជាអ្នកសម្របសម្រួល ឬជាទីប្រឹក្សា។ នៅក្នុងដំណាក់កាលនោះអ្នកនិងបានអនុវត្តន៍ការសម្តែងជាគំរូ ហើយអ្នកនិងក្រុមរបស់អ្នក នឹងមានគំនិតល្អៗស្តីអំពីសមត្ថភាព និង ចំណុចខ្លាំងនៃមនុស្សផ្សេងៗគ្នា ។

## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់



សូមទុកឱ្យក្រុមសម្រេចថាតើអ្នកណាគួរដើរតួ ។ វាពិតជារឿងលំបាកប្រសិនបើមានតួអង្គអាក្រក់ និង សាហាវនៅក្នុងសាច់រឿងដោយហេតុថាគ្មាននរណាម្នាក់ចង់ដើរតួអាក្រក់ទេ ។ ទោះជាយ៉ាងណាក៏ដោយមធ្យោបាយមួយគួរដោះស្រាយបញ្ហាឬទំនាស់ណាមួយនៅពេលដែលក្រុមបង្ហាញអត្ថបទសាច់រឿងនោះគឺត្រូវឱ្យគេចាប់ផ្តើមពិភាក្សាពីការបែងចែកតួសម្តែងឱ្យហើយ ។ ឧទាហរណ៍ ៖ ហេតុអ្វីបានជាមិនប្រើឈ្មោះពិតឱ្យហើយទៅនៅពេលដែលយើងរៀបចំតួនោះ?

ប្រសិនបើក្រុមមានអារម្មណ៍ថា "Julie" ជាអ្នកដែលល្អបំផុតក្នុងការសម្តែងនោះ ហើយនាងយល់ព្រមដែរនោះ ហេតុដូចម្តេចមិនហៅតួអង្គនោះ " Julie " តែម្តងទៅនៅក្នុងការសម្តែង? ធ្វើបែបនេះនិងនាំឱ្យអ្នកសិក្សាមានការងាយស្រួលទៀតផង ។



## សកម្មភាព ២ ៖ រឿងល្ខោន

### លំហាត់សម្តែងល្ខោន

ការបង្រៀន ២ វគ្គរួមជាមួយការសម និង សម្តែងនៅក្នុងបន្ទុករបស់អ្នកភាគច្រើន ប្រហែលជាមិនមានបទពិសោធន៍ជាមួយនឹងការសម្តែងល្ខោនពីមុនទេ។ ប្រសិនជាអ្នកមានសំណាងពួកគេខ្លះ ឬពួកគេទាំងអស់ធ្លាប់មានបទពិសោធន៍កាលពីមុន ។ ដូចនេះអ្នកគួរដឹងពីដំបូងថា មនុស្សពេញវ័យអាចនឹងទទួលប្រយោជន៍ជាច្រើនលើការងាររៀបចំដើម្បីជួយឱ្យពួកគេឈ្នះការខ្មាសអៀនពីធម្មជាតិ និង មានមនសិការដោយខ្លួនឯង ។

ហេតុដូច្នេះហើយវាតម្រូវឱ្យមានការសម្តែងសមជាមុន ។ ជាមូលដ្ឋានគោលបំណង គឺចង់ឱ្យមនុស្សវ័យក្មេងងាយស្រួលគិតគួរធ្វើឱ្យពួកគេមិនមានការព្រួយក្រែងអំពីការសម្តែងរបស់ពួកគេ ហើយប្រតិកម្មឬគំនិតអ្នកដទៃ គឺជាការបង្កើតទំនុកចិត្តរបស់ខ្លួន។

លំហាត់រឿងល្ខោនអាច នឹងប្រើប្រាស់នៅម៉ោងមុនពេលចាប់ផ្តើមសមពេញលេញ ។ ប្រសិនបើអ្នកមានអ្នកជំនាញល្ខោនធ្វើការជាមួយអ្នកអ្នកនោះអាចនឹងផ្តល់នូវលំហាត់ជាច្រើនដើម្បីឱ្យក្រុមនោះមានគំនិតច្បាស់លាស់ហើយនឹង ជួយឱ្យគេមានលក្ខណៈសម្បត្តិជាតួសម្តែង ។

ឧបសម្ព័ន្ធទី ១ នៃសៀវភៅសម្តែងតួមានការផ្តល់គំនិតយោបល់ស្តីពីលំហាត់សម្តែងល្ខោនជាច្រើន ។ មានលំហាត់ផ្សេងៗគ្នារាប់ពាន់ដែលមានតម្លៃស្មើៗគ្នា ។អ្នកក៏អាចទិញសៀវភៅស្តីពីការសម្តែងល្ខោនដែលពិពណ៌នាអំពីលំហាត់ផ្សេងៗទៀត។ សៀវភៅទាំងនោះ ក៏អាចមាននៅបណ្ណាល័យសម្រាប់ពិគ្រោះយោបល់។ ប៉ុន្តែយ៉ាងហោចណាស់អ្នកត្រូវធ្វើលំហាត់សម្តែងមួយសិនមុននឹងចាប់ផ្តើមសម្តែងទាំងស្រុងនោះ ។

### ការហាត់សម

ការធ្វើការជាមួយក្រុមមនុស្សវ័យក្មេងក្នុងការផលិតរឿងល្ខោន គឺជាការងារគួរឱ្យស្មុកស្មាញប៉ុន្តែវាជាការងារដែលគួរទទួលរង្វាន់ផងដែរ ។ ការដែលអ្នកសម្រេចថាត្រូវសមយ៉ាងណាសម្រាប់ក្រុមរបស់អ្នកនោះ គឺអាស្រ័យលើកត្តាជាច្រើនដែលបានលើកឡើងខាងលើទាក់ទងនឹងគោលបំណងនៃលំហាត់។ មិនតែប៉ុណ្ណោះគោលបំណងទាំងនេះមានការជាក់លាក់ណាមួយដែលត្រូវការពេលវេលា

និងកម្លាំងប៉ុណ្ណាក្នុងការសម្តែងមួយចប់រឿង។ ឧទាហរណ៍ ប្រសិនបើក្រុមសម្រេចចិត្តថាត្រូវសម្តែងផ្ទាល់ក្នុងការប្រកួតប្រជែង ឬក៏ត្រូវសម្តែងជាសាធារណៈអ្នកអាចចំណាយពេល ដើម្បីសមឱ្យបានកាន់តែច្រើនទៀតផងដែរ ។

លើសពីនេះទៅទៀត ការសមអាស្រ័យលើធនធានទីកន្លែងដែលមាន ។ ប្រសិនបើអ្នកធ្វើការក្នុងផ្នែកអប់រំក្នុងប្រព័ន្ធ សាលារបស់អ្នកអាចនឹងមានរោងល្ខោន ឬក៏ឆាកសម្តែងឬក៏បន្ទប់សិក្ខាសាលាជាដើម ។ប្រសិនបើអ្នកធ្វើការក្នុងអប់រំក្រៅប្រព័ន្ធ អ្នកប្រហែលជានឹងត្រូវរកទីកន្លែងសមរម្យមួយ ដូចជាសាលសហគមន៍ រោងសិល្បៈតូចមួយ ឬក៏រោងសិល្បៈធំណាមួយជាដើម ។ អ្នកអាចពឹងលើទីកន្លែងខាងក្រៅផងដែរ ។ អ្នកអាចគិតដល់លទ្ធភាពសម្តែងនៅរោងល្ខោនតាមផ្លូវ ។ អ្វីដែលក្រុមសម្រេចនឹងមានប្រសិទ្ធភាពជាក់លាក់ក្នុងការរៀបចំការសមជាក់ស្តែង ។

អ្នកត្រូវតែអត់ធ្មត់និងត្រូវមានកម្លាំងក្នុងការសមនានា។ តាមលក្ខណៈធម្មជាតិការសម្តែងអាចយូរហើយច្រំដែលៗ ហើយមនុស្សទាំងនោះអាចនឹងធុញទ្រាន់ក្នុងពេលនោះ ។ លើសពីនេះការសមតម្រូវឱ្យអ្នកផ្តោតការយកចិត្តទុកដាក់ទៅលើក្រុម និង បុគ្គលគ្រប់ៗគ្នាផងដែរក្នុងឱកាសផ្សេងៗក្នុងពេលខុសៗគ្នា ។ ឧទាហរណ៍អាចនឹងមានឈុតមួយ ដែលពាក់ព័ន្ធជាមួយតួអង្គតែ ២ នាក់ប៉ុណ្ណោះប៉ុន្តែឈុតនោះពោរពេញទៅដោយភាពរំភើបចិត្តហើយទាមទារឱ្យមានអ្នកបង្ហាត់មកហ្វឹកហ្វឺនបុគ្គលដែលត្រូវដើរតួនោះដែរ ។ តើអាចនឹងមានរឿងអ្វីកើតឡើងចំពោះអ្នក ១៥ នាក់ផ្សេងទៀតនៅក្នុងពេលនេះ ?

នៅពេលដែលមនុស្សវ័យក្មេងទាំងនោះធុញទ្រាន់ ហើយពួកគេមានទីធ្លាពួកគេនឹងត្រូវ ការចំណាយកម្លាំងរបស់ពួកគេ ដូច្នេះយើងត្រូវមានទីធ្លាសម្រាប់ពួកគេ ។ លើកទឹកចិត្តពួកគេឱ្យមានល្បែងដើម្បីសមដូចជាបាល់ទាត់ តេនីសឬបាល់បាស្កេត ឬអ្វីដែលពួកគេអាចលេងដោយសុវត្ថិភាព ក្តារល្បែង សៀវភៅកាសែត ទស្សនាវដ្តីជាដើម ។ ប្រសិនបើគេមានការងារផ្សេងធ្វើដូចជាកិច្ចការសាលា សូមឱ្យពួកគេយកមកតាមខ្លួននៅពេលសមផងចុះ ។

ការសម្តែងល្ខោនតម្រូវឱ្យមានការរៀបចំឆាក ហើយអ្នកអាចសុំឱ្យសមាជិកផ្សេងទៀតជួយរៀបចំការងារនេះ ។ វាអាចមានបទភ្លេង ចម្រៀង ឬ របាំ ហើយការរៀបចំទាំងនេះក៏ត្រូវការអនុវត្តន៏ផងដែររឿងសំខាន់គឺត្រូវដឹងថាការសមក៏អាចមានកំហុសដែរដោយសារមូលហេតុជាច្រើន ដូច្នេះត្រូវត្រៀមខ្លួនឱ្យបានល្អដើម្បីប្រឈមមុខ និងស្ថានភាពទាំងនេះ ហើយត្រូវវាងវៃ ក្នុងការរៀបចំ ។ គន្លឹះនៃការហ្វឹកហាត់ប្រកបដោយភាពរលូន គឺការមានប្រាស្រ័យទាក់ទងគ្នាបានល្អ ជាពិសេសនៅពេលដែលក្រុមនេះជាក្រុមថ្មីចំពោះការសម្តែងរឿងល្ខោន ។ពួកគេ នឹងចង់ដឹងឱ្យបានច្បាស់ប្រាកដថា តើត្រូវទៅកន្លែងណា, ឈរ អង្គុយនិងធ្វើសកម្មភាពនៅទីកន្លែងណា ។ ពួកគេនឹងចង់ដឹងថាតើត្រូវនិយាយនៅពេលវេលាណា និងនិយាយយ៉ាងដូចម្តេច ។ ពួកគេនឹងចង់ដឹងពីទីកន្លែងដែលគួរទៅនឹងគួរធ្វើអ្វីនៅពេលដែលពួកគេបានថ្លែងពីអ្វីដែលត្រូវយកមកនិយាយ ។ ប្រសិនបើអ្នកធ្វើការងារជាមួយប្រភេទរឿងល្ខោនជាក់លាក់ទាំងឡាយដូចជារឿងល្ខោនដែលត្រូវពាក់របាំងមុខជាដើមនោះក៏វាតម្រូវឱ្យមានការបកស្រាយពន្យល់ និងការគាំទ្រដោយយកចិត្តទុកដាក់ផងដែរ ។ ប្រការសំខាន់គឺពួកគេត្រូវដឹងថាខ្លួនអាចសួរសំណួរមួយដែលសំណួរនោះ នឹងត្រូវបានគេយកចិត្តទុកដាក់ ហើយឆ្លើយតបមកវិញទាន់ពេលវេលា ។



**ការសម្តែង**

វិធីមួយក្នុងការជួយតួរសម្តែងថ្មីៗគឺត្រូវធានាឱ្យបានច្បាស់លាស់ថានាដកថានៃការសម្តែងត្រូវពិស្តារក្បោះក្បាយដូចដែលអាចធ្វើបានហើយផ្តល់នូវការបង្ហាញតាមដំណាក់កាលលើឆាកបានល្អប្រសើរជាឧទាហរណ៏ដូចជាបង្ហាញដោយប្រាប់ឱ្យតួអង្គម្នាក់ថាខ្លួនត្រូវចាកចេញពីឆាកក្នុងខណៈដែលខ្លួនពោលនូវសម្តីបែបណាមួយ ។

ចូរកុំមើលស្រាលពេលវេលានិងកម្លាំងកាយដែលត្រូវចំណាយក្នុងការហ្វឹកហាត់ឱ្យសោះ ជាពិសេសប្រសិនបើអ្នកកំពុងរៀបចំខ្លួនសម្រាប់គោលបំនងជាក់លាក់មួយហើយកុំវាយតម្លៃទាបចំពោះរបៀបដែលក្រុមតួរទាំងនោះត្រូវសម្តែងជាក់ស្តែងនៅពេលដែលពេលវេលាមកដល់ ។

ឱកាសមុនពេលសម្តែង, ក្នុងពេលសម្តែង និងសកម្មភាពបន្តក្រោយពេលសម្តែងនឹងត្រូវអាស្រ័យសារជាថ្មីទៅលើគោលបំណងនៃសាច់រឿងដែលក្រុមបានកំណត់ទុកមក ។ ឧទាហរណ៍ ប្រសិនបើការសម្តែងល្ខោនត្រូវតែជាផ្នែកមួយនៃយុទ្ធនាការលើកម្ពស់ការយល់ដឹងឱ្យកាន់តែទូលំទូលាយថែមទៀតនោះក្រុមនេះនឹងអនុវត្តនូវមេរៀនដែលទទួលបានពីជំពូកប្រព័ន្ធផ្សព្វផ្សាយ "Media modules" នៅក្នុងរយៈពេលមុនសម្តែងនិងសកម្មភាពក្រោយពេលសម្តែង ។ម្យ៉ាងទៀត,ចំណុចសំខាន់ដែលយកចេញពីសៀវភៅជំពូកស្រាវជ្រាវ និងជំពូកការបញ្ចូលព័ត៌មាននិងសហគមន៍នេះនឹងមានសារៈសំខាន់ជាខ្លាំងក្នុងការពង្រីកលទ្ធផលនៃយុទ្ធនាការលើកកម្ពស់ការយល់ដឹង ឱ្យកាន់តែធំទូលាយថែមទៀត ។

លក្ខណៈនៃការសម្តែង នឹងមានការពាក់ព័ន្ធទៅនឹងទីកន្លែងពេលវេលានិងការត្រៀមរៀបចំជាមុន ។ ឧទាហរណ៍ដូចជាការរៀបចំសម្តែងនៅពេលថ្ងៃដែលជាគំនិតមួយមិនសមស្របឡើយព្រោះតាមទម្លាប់វាជាពេលដើផ្សារទិញឥវ៉ាន់សម្រាប់ក្រុមគ្រួសារហើយជាពេលដែលមិនមានមនុស្សច្រើនអាចទំនេរចូលរួមការសម្តែងនេះបាន ។

ត្រូវយល់ដឹងពីលទ្ធផលដែលក្រុមប្រាថ្នានឹងបង្កើតឱ្យមានព្រមទាំងដឹងពីចរិកលក្ខណៈរបស់អ្នកទស្សនាមុខសញ្ញាក្នុងពេលដែលចាត់ចែងការសម្តែង ។ ម្ចាស់ទីកន្លែងឬអ្នកចាត់ការក៏នឹងត្រូវដឹងអំពីការហ្វឹកហាត់របស់អ្នក និងកម្រិតពេលវេលានៃការសម្តែងនេះទាំងអស់ដើម្បីធានាឱ្យបានថាវាពុំប៉ះទង្គិចជាមួយនឹងទាមទាពីក្រុមផ្សេងៗទៀតឡើយ ។

គោលបំនងនៃការសម្តែងតួមានទិសដៅឆ្ពោះទៅរកក្រុមទស្សនិកជនដែលជាមុខសញ្ញា មានន័យថាផ្តល់ចំណេះដឹងអំពីលក្ខណៈធម្មជាតិ និង បុគ្គលិកលក្ខណៈរបស់ពួកគេ ។ នៅពេលដែលយើងកំណត់ក្រុមទស្សនិកជនដែលជាមុខសញ្ញាបានជាក់លាក់ ហើយនោះអ្នកក៏អាចរៀបគម្រោងទៅតាមនោះដែរ ។

ការស្រាវជ្រាវ គឺជាគន្លឹះសំខាន់ហើយអ្នកត្រូវនាំក្រុមឱ្យធ្វើការស្រាវជ្រាវ ។ សាច់រឿងល្ខោននិងការសម្តែងគឺជារបស់ពួកគេ ។ ដូច្នេះពួកគេត្រូវតែចូលរួមយ៉ាងសកម្មនៅគ្រប់ទិដ្ឋភាពក្នុងការសម្តែង ។





ប្រសិនបើអ្នកសម្តែងជាសាធារណៈអ្នកត្រូវយកចិត្តទុកដាក់លើទិដ្ឋភាពដូចខាងក្រោម ៖

**-សំបុត្រល្ខោន ៖** តើអ្នកនឹងយកតម្លៃចូលទស្សនាទេ ? តើនឹងត្រូវលក់សំបុត្រជាមុនឬទេ ឬក៏ត្រូវលក់នៅនឹងមាត់ទ្វារតែម្តង តើអ្នកជូនប្រអប់ទៅទស្សនិកជនដើម្បីឱ្យពួកគេចូលថវិកាជាទានទៅតាមជម្រើសរបស់គេឬ ?

**-ការផ្សព្វផ្សាយៈ** តើអ្នកនឹងជូនដំណឹងដល់មហាជនដោយវិធីណាចំពោះព្រឹត្តិការណ៍នោះ ? តើអ្នកនឹងចែកចាយព័ត៌មាននោះតាមសារាចរ ឬ តាមរយៈក្រដាស poster នៅក្នុងតំបន់នោះឬទេ ?

**-កម្មវិធី ៖** តើអ្នកនឹងចែកចាយកម្មវិធីដែលបោះពុម្ពសម្រាប់ព្រឹត្តិការនោះឬទេ? តើអ្នកនិងបញ្ចូលនូវការផ្សាយពាណិជ្ជកម្មសម្រាប់ជំនួញក្នុងស្រុក ដើម្បីទប់ទល់ចំណាយក្នុងការផលិតឬទេ ? តើអ្នកយកតម្លៃវាឬទេ ? មានកម្មវិធីក៏ជាឱកាសដ៏ល្អមួយដែរ ដើម្បីឱ្យតម្លៃដល់ក្រុមរបស់អ្នកហើយជាការល្អសម្រាប់ជួយអ្នក និងជាឱកាសអរគុណអ្នកគាំទ្រផងដែរ ។

សូមឱ្យក្រុមចូលរួមក្នុងការសម្រេចនិងការរៀបចំទាំងនេះ ។ កុំចំណាយលើអ្វីដែលមិនចាំបាច់ ឬ អ្វីដែលមិនសំខាន់ ។ ចូរប្រើធនធានដែលមានស្រាប់ហើយត្រូវធ្វើយ៉ាងណាឱ្យការសម្តែងអាចប្រព្រឹត្តទៅបាន ។ អ្នកអាចពិចារណាលើផលប្រយោជន៍ក្នុងការផលិតវីដេអូការសម្តែងនោះ ។ ការថតនេះអាចនឹងជួយយើងបានជាច្រើនដូចជា ៖

- ប្រសិនបើការសម្តែងគឺជាផ្នែកមួយនៃឈុតវីដេអូនោះអាចនឹងជួយសម្រួលក្នុងការសមនៅថ្ងៃមុខ ។
- វីដេអូនោះអាចនឹងត្រូវប្រើប្រាស់ដោយសារព័ត៌មានក្នុងការផ្សព្វផ្សាយស្តីពីការសម្តែង ។
- ក្រុមសម្តែង ឬ ក្រុមគ្រួសារអាចនឹងត្រូវការ ការសែត ក្នុងការសម្តែងនោះដែរសម្រាប់អនុស្សាវរីយ៍ការងារ និង ការតាំងចិត្តរបស់ពួកគេ ។
- វាអាចត្រូវយកទៅប្រើប្រាស់ជាឧបករណ៍គរុកោសល្យសម្រាប់ក្រុមដទៃទៀត ។

- វាអាចត្រូវយកទៅប្រើប្រាស់ជាឧបករណ៍ក្នុងការឃោសនាលើកកម្ពស់ការយល់ដឹងស្តីអំពីពលកម្មរបស់កុមារ ។
- វាអាចត្រូវបានគេផ្ញើរជូនទៅ IPEC ដើម្បីពង្រឹងផ្នែកគរុកោសល្យ និងជាធនធានឃោសនាលើកកម្ពស់ការឃោសនាជាសកលដើម្បីបំបាត់ការប្រើពល-កម្មកុមារ ។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



-ត្រូវធ្វើយ៉ាងណាឱ្យក្រុមសកម្មទាំងនោះមានគុណភាពល្អ និងធ្វើការគាំទ្រចំពោះលំហាត់នោះជាវិជ្ជមាន ។

-ត្រូវធ្វើយ៉ាងណាឱ្យអ្នកគ្រប់គ្នាចូលរួម

-ត្រូវធ្វើយ៉ាងណាឱ្យបរិយាកាសនោះមាននិរន្តភាពទាំងការរៀបចំអត្ថបទ សាច់រឿង និង ការសមសម្តែងបើមិនដូចនោះទេក្រុមនោះ អាចនិងបាត់បង់ចំណាប់អារម្មណ៍ហើយអាចនិងរកអ្វីផ្សេងទៀតធ្វើទៅតាមកម្លាំង និងការស្រមើស្រម៉ៃរបស់ពួកគេ ។



-ត្រូវអនុញ្ញាតឱ្យមានការផ្លាស់ប្តូរយោបល់នៅក្នុងក្រុមនៅពេលដែលពួកគេបង្ហាញសាច់រឿង និងនៅពេលដែលពួកគេចូលរួមការសមនានា។ ត្រូវធ្វើយ៉ាងណាឱ្យវាមានចិត្តល្អ និងជាលក្ខណៈធម្មជាតិ។ គោលបំណង គឺចង់បង្កើតទំនុកចិត្តរបស់បុគ្គលម្នាក់ៗមិនមែនបង្អាប់ឡើយ ។

-សូមកុំឱ្យមានការរិះគន់ ឬប្រើភាសាអាក្រក់ នៅក្នុងវគ្គនីមួយៗ។ វាអាចនាំឱ្យមានជម្លោះ និងការបែកបាក់ក្រុមសកម្មនោះ ។

-សូមកុំឱ្យមានក្រុមតូចណា ឬបុគ្គលណាធ្វើឱ្យពួកគេទាំងអស់អាម៉ាស់មុខឱ្យសោះ។ ប្រសិនបើអ្នកឃើញថានរណាម្នាក់កំពុងតែតស៊ូសរសេរ ឬសម្តែងអ្វីនោះ សូមជួយពួកគេឱ្យបានសម្រេច។ រួមចំណែកក្នុងការងាររបស់ពួកគេ។ ប្រសិនបើពួកគេ "មានបញ្ហារាំងស្ទះ" នៅពេលសមសូមចូលទៅជួយពួកគេ ឬក៏ឱ្យពួកគេឱនគោរពដោយសេចក្តីថ្លៃថ្នូរ ។

-សូមឱ្យប្រើពាក្យផ្អែមល្ហែម ស្និទ្ធស្នាល និង យកចិត្តទុកដាក់ចំពោះសមាជិកនៃក្រុមអសមត្ថភាព។ ល្ខោនគឺមានអំណាចគ្រប់គ្រាន់ក្នុងការជួយដោះស្រាយជា

មួយក្រុមអសមត្ថភាព ហើយជា ឱកាសមួយដើម្បី សម្រេចរឿងនោះផងដែរ ។ករណីនេះអាចប្រើប្រាស់សម្រាប់បុគ្គលទាំងឡាយណា ដែលធ្លាប់ទទួលការឈឺចាប់យ៉ាងខ្លាំងនៅ ក្នុងជីវិតរបស់ពួកគេអាចជាការប៉ះទង្គិចផ្លូវចិត្ត និងផ្លូវកាយ ។ ការប៉ះទង្គិចនេះអាចនិងធ្វើឱ្យពួកគេខូចចិត្តឬធ្វើឱ្យពួកគេមានកង្វល់ ហើយវាជារឿង មួយសំខាន់ណាស់ ដែលអ្នកយល់ដឹងនូវការវិវឌ្ឍន៍បែបនេះ ហើយអ្នកគាំទ្របុគ្គលទាំងនោះនៅពេលដែលចាំបាច់ ។ អ្នកគួរបើកទូលាយឱ្យមានការទំនាក់ទំនងរវាងឪពុកម្ដាយ និង អាជ្ញាធរនានាដើម្បីឱ្យជួយសម្រួលដំណើរការនេះបាន ។

-សូមប្រើម៉ាស៊ីនថតវីដេអូប្រសិនបើអ្នកមាន ។ វាអាចជួយក្នុងដំណើរការវាយតម្លៃ ហើយមនុស្សវ័យក្មេងទាំងនោះនិងមានអារម្មណ៍ល្អ នៅពេលបានឃើញរូបភាពខ្លួនឯងនៅក្នុងវីដេអូ ។

-សូមប្រើវគ្គដែលអាចឱ្យមានការសួរនាំគ្នានៅក្នុងគំរូរឿងល្ខោនឱ្យបានត្រឹមត្រូវ ហើយទុកឱកាសឱ្យក្រុមបញ្ចេញមតិបានទូលំទូលាយ និង ដោយសេរីក្នុងចំណោមពួកគេ ។ សូមទុកឱ្យពួកគេសម្រាកលំហែរ និង បានសើចលេង ហើយធ្វើឱ្យពួកគេចាប់ផ្តើមទទួលនូវបទពិសោធន៏តាមរយៈនៃការគិតគូរជាប្រព័ន្ធរបស់ពួកគេ ។

-ត្រូវមានមហិច្ឆតាចំពោះក្រុមរបស់អ្នក និង លើកទឹកចិត្តពួកគេឱ្យមានមហិច្ឆតាផងដែរ ។ រឿងល្ខោនរបស់ពួកគេនឹងបង្កើននូវឥទ្ធិពលជាក់លាក់មួយនៅក្នុងសង្គមជាក់ស្តែងហើយមានលក្ខណៈទូលំទូលាយ ។ សម្រាប់មនុស្សវ័យក្មេងដែលអាចបង្ហាញនូវប្រតិកម្មបែបនេះ ពួកគេពិតជាផ្តល់នូវឥទ្ធិពលទំនុកចិត្តដល់ពួកគេតម្លៃរបស់ពួកគេក្នុងការយល់ដឹងស្តីពីអំណាចនៃសិល្បៈ និងតួនាទីរបស់ពួកគេជាភ្នាក់ងារប្រមូលកម្លាំងសង្គម និងផ្លាស់ប្តូរសង្គម ។

## ការពិភាក្សាបញ្ចប់

## បង្រៀន ១ពេល



ការពិភាក្សាលម្អិតសម្រាប់សៀវភៅនេះគួរត្រូវធ្វើបន្ទាប់ពីការសម្តែងរឿងល្ខោនចប់ ។ សូមជ្រើសរើសកន្លែងដែលងាយស្រួលដើម្បីធ្វើការពិភាក្សានេះ ។ សូមកុំព្យាយាម ឬធ្វើការពិភាក្សានៅពេលដែលក្រុមកំពុងជាប់រវល់ ឧទាហរណ៏ក្នុងអំឡុងពេលសម ឬក៏ភ្លាម១បន្ទាប់ពីពេលសម្តែងចប់នោះ ។

រៀបចំក្រុមឱ្យបានស្រួល ហើយប្រមូលផ្ដុំឯកសារកុងត្រារបស់អ្នក ។ ក្នុងករណីមានការគាំទ្រខាងក្រៅសូមអញ្ជើញបុគ្គលនោះឱ្យចូលរួមនៅក្នុងវគ្គពិភាក្សានេះ។ សៀវភៅទាំងនេះត្រូវបានរៀបចំឡើងដើម្បីបង្កើនការយល់ដឹងក្នុងចំណោមមនុស្សវ័យក្មេង និងដើម្បីលើកកម្ពស់ការឆ្លើយតបផ្នែកអារម្មណ៍របស់ពួកគេចំពោះពលកម្មកុមារក្នុងគោលបំណងបញ្ចូលការគាំទ្ររបស់ពួកគេទៅក្នុងយុទ្ធនាការឃោសនាជាសកល ដើម្បីលុបបំបាត់កម្លាំងពលកម្មកុមារនេះតាមរយៈរឿងល្ខោន យើង និងទទួលបាននូវកម្រិតការយល់ដឹង និង ការឆ្លើយតបកាន់តែស៊ីជម្រៅតាមរយៈការសម្ដែង និង ដំណើរការនៃការដើរតួនានា មនុស្សវ័យក្មេងទាំងនោះប្រាកដជាចូលតួ និងយល់ដឹងអំពីពួកគេ ហើយអាចធ្វើត្រាប់អារម្មណ៍ និងសកម្មភាពរបស់ពួកគេឡើងវិញ ។ វាជាវិធីសាស្ត្រនៃសិក្សាដ៏មានប្រសិទ្ធិភាពហើយវា និងមានផលប៉ះពាល់ជាក់លាក់ចំពោះពួកគេទៀតផង ។

ក្នុងចំណោមសៀវភៅទាំងអស់នេះសៀវភៅល្ខោនបង្ហាញនូវវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុតក្នុងការជួយមនុស្សវ័យក្មេងឱ្យយល់ដឹង មានអារម្មណ៍ថាអ្វីទៅជាពលកម្មកុមារនោះ ហើយដែលអាចនឹងប៉ះពាល់ដល់កុមារនៅក្នុងស្ថានភាពទន់ខ្សោយនោះ ។ វានឹងលើកកម្ពស់ការយល់ដឹងរបស់ពួកគេស្ដីពីសិទ្ធជាមូលដ្ឋានរបស់កុមារ ។ លើសពីនេះវាក៏ជំរុញឱ្យកុមារទទួលយកអំណាចកាន់តែឆាប់រហ័សពួកគេមានការអភិវឌ្ឍន៍ផ្នែកអារម្មណ៍ជាម្ចាស់នៃបញ្ហានៅពេលដែលពួកគេបញ្ចប់ការសម្ដែងនីមួយៗ ហើយនៅក្នុងតំណាក់កាលនេះ គេសង្ឃឹមថាពួកគេនិងចាប់ផ្ដើមដឹងថាវាជាបញ្ហាមួយដែលជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូបទូទាំងសកលលោក ហើយដែលពួកគេមានតួនាទីបញ្ចប់បញ្ហាទាំងនេះផងដែរ ។ លើសពីនេះពួកគេចាប់ផ្ដើមយល់អំពីឥទ្ធិពលនៃការសម្ដែងល្ខោនដែលបញ្ជូន និងផ្ដល់នូវព័តិមានដល់សមាជិកដទៃទៀតនៅក្នុងសង្គម ។ តាមរយៈការសម្ដែងសិល្បៈពួកគេអាចផ្ដល់នូវព័តិមាននោះ ដល់មនុស្សគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ។

សូមលើកឡើងនូវទិសដៅទាំងនេះជូនដល់មនុស្សវ័យក្មេង នៅក្នុងក្រុមរបស់អ្នក។ សូមនិយាយជាមួយពួកគេតាមកម្រិតនៃការយល់ដឹងរបស់ពួកគេ ។ ផ្សព្វផ្សាយក្នុងចំណោមពួកគេហើយជំរុញលើកទឹកចិត្តពួកគេ។ សូមប្រាប់ពួកគេថាការឃោសនានេះត្រូវមានការជួយជ្រោមជ្រែង និង ការគាំទ្រពួកគេ ។ យើងកំពុងតែ

ផ្តោតការយកចិត្តទុកដាក់លើយុវជននៃសង្គមសព្វថ្ងៃនេះដើម្បីផ្តល់នូវកម្លាំងក្នុងការ ឃោសនា ដើម្បីបំបាត់ពលកម្មកុមារ ។ សូមធ្វើឱ្យពួកគេមានមហិច្ឆតា និង នាំឱ្យពួកគេមានមោទនភាព ។ នេះគឺជាកំណត់សំគាល់ជាវិជ្ជមានដែលអ្នកគួរតែបញ្ចប់វគ្គនេះ ។ ការរួមចំណែករបស់ពួកគេ គឺសំខាន់ដូចក្រុមដទៃទៀតនៅក្នុងសង្គមនេះដែរ បើមិនដូច្នេះទេពួកគេនិងជាដៃគូនៃកម្លាំងកុមារដែលពួកគេនឹងជួយ ។ វគ្គពិភាក្សាលម្អិតនេះនឹងជួយឱ្យក្រុមដឹងនូវទំហំនៃអ្វីដែលពួកគេទើបតែបានធ្វើតាមរយៈការសម្តែងរឿងល្ខោន ។ គេនឹងយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះការបន្តតាមដាន និងការសម្តែងផ្សេងៗទៀតដែលពួកគេនឹងត្រូវធ្វើនោះ ។ វាគឺជាបទពិសោធន៍ដ៏ល្អបំផុតក្នុងការឈរពីក្រោយទស្សនិកជនហើយមើលក្រុមរបស់អ្នកសម្តែងហើយអ្នកនឹងឃើញយ៉ាងជាក់លាក់ថាទស្សនិកជនមានប្រតិកម្មយ៉ាងណានោះ។ ការមើលទឹកមុខរបស់ពួកគេនៅពេលដែលបើកវាំងននឡើងនោះវាជាឱកាសមានតម្លៃណាស់ហើយវាអាចនឹងជំរុញឱ្យអ្នកគិតថាតើគួររកបទពិសោធន៍បន្ថែមទៀត ហើយត្រូវបង្កើតនូវការឃោសនាពិតប្រាកដដែលប្រកបដោយនិរន្តរភាព ឬទេ ឬក៏ត្រូវរកបទពិសោធន៍ថ្មីផ្សេងទៀត ដោយធ្វើការជាមួយក្រុមដទៃទៀតនោះ ។

## ការវាយតម្លៃ និង សកម្មភាពបន្ត

ចំណុចសំខាន់សម្រាប់ឱ្យយើង វាយតម្លៃផលប៉ះពាល់នៃគំរូរនេះ គឺការបង្កើតឡើងនូវរឿងល្ខោនខ្លីមួយដោយមានកម្រិតនៃការចូលរួមនៃក្រុមយុវជនអាចធ្វើទៅបាន ។ លើសពីនេះអ្នកគួរតែពិនិត្យឱ្យបានច្បាស់លាស់លើការវិវឌ្ឍន៍ផ្ទាល់របស់ក្រុម និង សមាជិកម្នាក់ៗនៅពេលដែលពួកគេចូលរួមក្នុងសកម្មភាពផ្សេងៗនៅក្នុងសៀវភៅនេះ។



សូមកត់សំគាល់ការរីកចម្រើននៃទំនុកចិត្តខ្លួនឯង និង ការឱ្យតម្លៃខ្លួនឯង និងការផ្លាស់ប្តូរកម្រិតនៃភាពចាស់ទុំនិងការយល់ដឹងផ្ទាល់ខ្លួនរបស់ពួកគេ ។ អ្នកក៏អាចកត់សំគាល់លើការសម្តែងរបស់សមាជិកម្នាក់ៗ ដែលផ្តោតអារម្មណ៍ក្នុងការសម្តែង និងការស្រលាញ់ពីសិល្បៈ ។

ការសម្តែងល្ខោនគឺជាឧបករណ៍មានឥទ្ធិពលពិតប្រាកដមួយ ។ វាជួយឱ្យយុវជនមានគំនិតផ្តោតអារម្មណ៍ទៅលើពលកម្មកុមារហើយអាចជួយការឃោសនា

ជាសាកលដើម្បីលុបបំបាត់ពលកម្មកុមារនោះ ។ សៀវភៅជំរុញឱ្យមាននិរន្តភាព នៅពេលដែលកម្មវិធីនោះដំណើរការ ។ តាមរយៈការសម្តែងរឿងល្ខោនជូនទស្សនិកជន សមាជិកក្នុងក្រុមរបស់អ្នកនឹងក្លាយជាភ្នាក់ងារដែលធ្វើឱ្យសង្គមមានការប្រែប្រួលប្រកបដោយសុវត្ថិភាព ។ ពួកគេអប់រំអ្នកដទៃនៅក្នុងសមាគមន៍ ហើយជួយឱ្យអ្នកទាំងនោះយល់ថាហេតុអ្វីបានជាពួកគេគួរដូរទ្ធវចរិត និងឥរិយាបថរបស់ពួកគេ ។ ពួកគេជួយអ្នកទាំងនោះឱ្យយល់អំពីស្ថានភាពនៃកម្លាំងពលកម្មកុមារជាសកល ហើយនិងធ្វើចំណាត់ការដើម្បីជួយកុមារទាំងនោះ ។

អ្នកគួរទុកឯកសារគ្រប់វគ្គសិក្សារបស់អ្នក ហើយគួរធ្វើកំណត់សំគាល់លើខ្សែវីដេអូ ដែលអ្នកអាចធ្វើបានព្រោះថាគំនិត និង ការចូលរួមចំណែកខ្លះអាចនឹងត្រូវប្រើប្រាស់និងមានប្រយោជន៍សម្រាប់សកម្មភាពនៅក្នុងសៀវភៅផ្សេងទៀត ។ ប្រសិនបើបទពិសោធន៍របស់អ្នកនៅក្នុងសៀវភៅនេះមានលក្ខណៈវិជ្ជមាន ហើយមានឥទ្ធិពល (អំណាច) នោះយើងសូមឱ្យអ្នកមើលសៀវភៅ ដែលមានចំណងជើងថា: សមាហរណកម្មសហគមន៍ដែលជាជំហានចុងក្រោយក្នុងដំណើរការនៃគរុកោសល្យនោះ ។

អ្នកអាចមានអារម្មណ៍ថា ការសម្តែងរឿងល្ខោនខ្លីនោះគឺជាការផ្តល់ការយល់ដឹងខ្ពស់បំផុតអំពីគម្រោងរបស់អ្នក និងរកការអនុវត្តន៍សៀវភៅទាំងនេះ ។ ទោះជាយ៉ាងណាសូមចងចាំថាសមាហរណកម្មរបស់សហគមគឺជាមធ្យោបាយគោលមួយ ដែលនាំឱ្យសៀវភៅទាំងនេះត្រូវបានស្ថាបនាឡើង ។

អ្នកគួរប្រមើលមើលលទ្ធភាពធ្វើការឃោសនាតាមរយៈការសម្តែងល្ខោនជាមធ្យោបាយសំខាន់របស់អ្នក ។ ទោះបីមានការសម្រេចចិត្តយ៉ាងណាក៏ដោយសូមអ្នកកុំភ្លេចផលប៉ះពាល់ចំពោះយុវជនតាមរយៈបទពិសោធន៍ពីការងារដែលអ្នកបាននឹងកំពុងធ្វើនៅក្នុងសៀវភៅទាំងនេះ ។ ជាក់ស្តែងបទពិសោធន៍នេះនឹងធ្វើឱ្យជីវិតរបស់ពួកគេមានការប្រែប្រួល ។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡុង សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# ✕ បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


### សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឌី ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217